**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

## សេចក្តីជូនដំណឹងសម្រាប់ប្រព័ន្ធសារព័ត៌មាន
## ស្តីពីពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងហិរញ្ញប្បទានសហប្រតិបត្តិការ
## រវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់

នាព្រឹកថ្ងៃព្រហស្បតិ៍ ២ កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣ ត្រូវនឹងថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩ នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយឯកឧត្តម Christian Berger ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ប្រចាំនៅកម្ពុជា បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងហិរញ្ញប្បទានសហប្រតិបត្តិការចំនួន ២ ដែលមានទឹកប្រាក់សរុបចំនួន **៦៧,១ លានអឺរ៉ូ** (ប្រមាណជា ៧៤ លានដុល្លារអាមេរិក)។ កិច្ចព្រមព្រៀងទាំង ២ មានដូចខាងក្រោម÷

### ១- កិច្ចព្រមព្រៀងហិរញ្ញប្បទានសហប្រតិបត្តិការ ឆ្នាំ២០១៨

តាមរយៈកិច្ចព្រមព្រៀងហិរញ្ញប្បទានសហប្រតិបត្តិការឆ្នាំ ២០១៨ នេះ ដែលជាកិច្ចព្រមព្រៀងក្របខ័ណ្ឌ រដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ នឹងផ្តល់ឥណទានសម្បទានចំនួន ៣០ លានអឺរ៉ូ និងហិរញ្ញប្បទានឥតសំណងចំនួន ២ លានអឺរ៉ូ សម្រាប់ហិរញ្ញប្បទានលើគម្រោងប្រសិទ្ធិភាពថាមពលសម្រាប់ការផ្គត់ផ្គង់អគ្គិសនីជនបទ។ ឥណទានសម្បទានចំនួន ៣០ លានអឺរ៉ូ គឺឥណទានសម្បទានទី ១ ដែលភាគីអាល្លឺម៉ង់ហៅថា "Reduced Interest Loan" នឹងត្រូវបានផ្តល់តាមរយៈធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ (KfW) ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងចុះហត្ថលេខាលើកិច្ចព្រមព្រៀងឥណទាន ជាមួយធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ (KfW) នៅពេលក្រោយទៀត ដើម្បីទទួលបានឥណទានមកប្រើប្រាស់សម្រាប់អនុវត្តគម្រោងប្រសិទ្ធិភាពថាមពលសម្រាប់ការផ្គត់ផ្គង់អគ្គិសនីជនបទ ។

### ២- កិច្ចព្រមព្រៀងហិរញ្ញប្បទានសហប្រតិបត្តិការ ឆ្នាំ២០១៩

តាមរយៈកិច្ចព្រមព្រៀងហិរញ្ញប្បទានសហប្រតិបត្តិការឆ្នាំ ២០១៩ នេះ ដែលជាកិច្ចព្រមព្រៀងក្របខ័ណ្ឌ រដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ នឹងផ្តល់ឥណទានសម្បទានចំនួន ៣០ លានអឺរ៉ូ សម្រាប់ហិរញ្ញប្បទានលើគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទសម្រាប់កម្ពុជា និង ហិរញ្ញប្បទានឥតសំណងចំនួន ៥,១ លានអឺរ៉ូ សម្រាប់គាំទ្រការធ្វើហិរញ្ញប្បទានលើគម្រោងជាក់លាក់មួយចំនួនទៀត។

ឥណទានសម្បទានចំនួន ៣០ លានអឺរ៉ូ ជាឥណទានសម្បទានទី ២ ពីរដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ដែលនឹងត្រូវបានផ្តល់តាមរយៈធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ (KfW) ផងដែរ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងចុះហត្ថលេខាលើកិច្ចព្រមព្រៀងឥណទាន ជាមួយធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ (KfW) នៅពេលក្រោយទៀត ដើម្បីទទួលបានឥណទានមកប្រើប្រាស់សម្រាប់អនុវត្តគម្រោងជាក់ស្តែង។ គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទសម្រាប់កម្ពុជា នឹងត្រូវបានធ្វើសហហិរញ្ញប្បទានជាមួយដៃគូអភិវឌ្ឍន៍មួយចំនួនទៀត ដូចជា ទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍ (AFD) និងសហគមន៍អឺរ៉ុបតាមរយៈមូលនិធិវិនិយោគអាស៊ី-អឺរ៉ុប (EU/AIF)។

ថ្លែងក្នុងឱកាសនោះ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** បានគូសបញ្ជាក់ថា រដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ គឺជាដៃគូអភិវឌ្ឍន៍ប្រទេសអឺរ៉ុប ទី២ បន្ទាប់ពីរដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង (ប្រទេសបារាំងបានចាប់ផ្តើមផ្តល់ឥណទានសម្បទានទី ១ របស់ខ្លួនដល់កម្ពុជានៅឆ្នាំ ២០១៣) ដែលបានផ្តល់ឥណទានសម្បទានដល់កម្ពុជា ដើម្បីរួមចំណែកក្នុងការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍ និងវិស័យអាទិភាពនានារបស់រាជរដ្ឋាភិបាលកម្ពុជា។ ការបើកទ្វារឥណទានពីដៃគូទ្វេភាគីថ្មីៗបន្ថែមទៀត ជាពិសេស ពីប្រទេសមានការអភិវឌ្ឍខ្ពស់នៃទ្វីបអឺរ៉ុប ដូចជា សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ និងសាធារណរដ្ឋបារាំង បានឆ្លុះបញ្ចាំងយ៉ាងជាក់ច្បាស់ថា ដៃគូអភិវឌ្ឍន៍សំខាន់ៗរបស់កម្ពុជា មានជំនឿយ៉ាងមុតមាំថា រាជរដ្ឋាភិបាលកម្ពុជាកំពុងដើរនៅលើផ្លូវត្រូវ លើយុទ្ធសាស្ត្រ និងគោលនយោបាយគ្រប់គ្រងបំណុលសាធារណៈរបស់ខ្លួន ប្រកបដោយភាពជឿជាក់ និងសមត្ថភាពគ្រប់គ្រាន់ និងរឹងមាំ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី បានសង្កត់ធ្ងន់ថា ពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងហិរញ្ញប្បទានសហប្រតិបត្តិនេះ គឺជាព្រឹត្តិការណ៍ដ៏សំខាន់មួយដែលឆ្លុះបញ្ចាំងអំពីកិច្ចសហប្រតិបត្តិការជាមិត្តភាពរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ក្នុងការជួយគាំទ្រដល់កិច្ចអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចនៅកម្ពុជា ដោយភាគីមិត្តប្រកាន់ខ្ជាប់នូវគោលនយោបាយ ផ្តល់ឥណទានសម្បទានរបស់ខ្លួន ឆ្លើយតបទៅនឹងសេចក្តីត្រូវការជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា និងក៏បានបង្ហាញអោយឃើញនូវការជឿទុកចិត្ត និងការវាយតម្លៃខ្ពស់របស់រដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ក្នុងការចូលរួមអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និង ឯកសារយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩-២០២៥ របស់រាជរដ្ឋាភិបាលកម្ពុជា និយាយជារួម គឺឆ្លើយតបទៅនឹងវិស័យអាទិភាពទាំង ៤ របស់រាជរដ្ឋាភិបាល គឺ **មនុស្ស, ផ្លូវ, ភ្លើង និងទឹក** ក្រោមការដឹកនាំដ៏ឈ្លៀសវៃ ប៉ិនប្រសប់ប្រកបដោយចក្ខុវិស័យ និងគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**។